# ព្រះរាជក្រម

## យើង

នស/រកម/០១១៩/០០៣

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ទទួលបញ្ជី
លេខ ៣៥៧
ថ្ងៃទី ៣០/១ ឆ្នាំ ២០១៩ ម៉ោង ៥:៣០
បញ្ជូនទៅ ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៨៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៩៩/០០២/២០១៩ កបធ.ច ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស
## ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត
## ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក
## ក្រុមប្រឹក្សាខណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.–**

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

-ជំពូកទី៣ (អំពីថវិកា) និងជំពូកទី៥ (អំពីអន្តរប្បញ្ញត្តិ) ត្រូវលុបចោល

-ជំពូកទី៤ ត្រូវបានកែប្រែមកជា ជំពូកទី៣ ថ្មី (អំពីទោសប្បញ្ញត្តិ)

- ជំពូកទី៦ ត្រូវបានកែប្រែមកជា ជំពូកទី៤ ថ្មី (អំពីអវសានប្បញ្ញត្តិ)

-មាត្រា ១១ មាត្រា ៨៥ មាត្រា ៨៦ មាត្រា ៨៧ និងមាត្រា ៨៨ ត្រូវលុបចោល

-មាត្រា៣ មាត្រា ១០ មាត្រា១២ មាត្រា១៣ មាត្រា១៣(ស្ទួន) មាត្រា១៧ មាត្រា២៩ មាត្រា៣០ មាត្រា៤៤ មាត្រា៤៦ មាត្រា៥៥ មាត្រា៥៧ មាត្រា៥៨ និងមាត្រាទាំងឡាយចាប់ពីជំពូកទី៤ ដល់ជំពូកទី៦ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

**មាត្រា ៣.– ថ្មី**

បទប្បញ្ញត្តិដូចមានចែងនៅក្នុងមាត្រា១៨ថ្មី នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកមកអនុវត្តសម្រាប់កំណត់ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ។

**មាត្រា ១០.– ថ្មី**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវអនុវត្តតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ១១.– ថ្មី (មាត្រា ១២ ចាស់)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំតាក់តែងបទបញ្ជា និងនីតិវិធីដែលទាក់ទងទៅនឹងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដោយអនុលោមទៅតាមគោលការណ៍នៃច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ១២.- ថ្មី

**ក**. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយត្រូវបែងចែកអាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដែលផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌល តាមជំហានទាំងឡាយដូចខាងក្រោម៖

**ជំហានទី១** ៖ កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបមកចែកនឹងចំនួនអាសនៈសរុបរបស់ក្រុមប្រឹក្សា តាមរូបមន្តដូចខាងក្រោម៖

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ ៖

- $ក_{ត}$ ៖ តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់ ២ខ្ទង់ក្រោយក្បៀស។
- $ស_{ស}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។
- $អ_{ស}$ ៖ តាងឱ្យចំនួនអាសនៈសរុបនៅក្នុងក្រុមប្រឹក្សា។

**ជំហានទី២** ៖ កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ បានទទួលនៅក្នុងក្រុមប្រឹក្សា។

រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ៖

$$អ_{ឆ} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ ៖

- $អ_{ឆ}$ ៖ ជាផលចែកដោយមិនគិតសំណល់ចែកតាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗមានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយនៅក្នុងជំហានទី៣។
- $ស_{ប}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។
- $ក_{ត}$ ៖ តាងឱ្យកូតាដែលបានកំណត់នៅក្នុងជំហានទី១។

បន្ទាប់ពីគណនាគ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងជំហានទី ២ ហើយប្រសិនគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាសនៈដែលនៅសល់ទាំងនេះត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទី៣។

**ជំហានទី៣** ៖ អាសនៈដែលនៅសល់ត្រូវបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលមានសិទ្ធិទទួលបាននៅក្នុងក្រុមប្រឹក្សា ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត។

រូបមន្តដូចខាងក្រោម ត្រូវអនុវត្តជាច់ដោយឡែកពីគ្នាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ធ}+១}$$

ក្នុងនោះ ៖

- $ម_{ធ}$ ៖ តាងឱ្យមធ្យមភាគខ្ពស់បំផុត។
- $ស_{ប}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។
- $អ_{ធ}$ ៖ តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។

ក្នុងករណីនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទី៣ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត។

ក្នុងករណីនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី៣ ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត។ បន្ទាប់មកត្រូវអនុវត្តតាមរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ $អ_{ធ}$ ចំនួន ១ ចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ។ ដូច្នេះអាសនៈចំនួនមួយ ត្រូវផ្តល់ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុតក្នុងការអនុវត្តរូបមន្តលើកទីពីរ។ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកម្តងមួយអាសនៈជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់។

**ខ**. ការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀងដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ។

**គ**. ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះ ត្រូវបានប្រកាសថាជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារបស់សាមីគណបក្សនយោបាយ។

**ឃ**. ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុដូចមានចែងក្នុងចំណុច **គ** នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនយោបាយនោះឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជន ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពីទទួលបានសំណើ។